ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:១៦១.សសរ..

**សេចក្តីសម្រេច**

**ស្តីពី**

**ការតែងតាំងសមាសភាពលេខាធិការដ្ឋានគណៈកម្មាធិការផលិតភាពកម្ពុជា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៦៧ អនក្រ. បក ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការផលិតភាពកម្ពុជា
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ១៦០ សសរ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការបង្កើតលេខាធិការដ្ឋានគណៈកម្មាធិការផលិតភាពកម្ពុជា
- យោងតាមសំណើរបស់ប្រធានគណៈកម្មាធិការផលិតភាពកម្ពុជា



www.pheakdeylaw.com

## សម្រេច

**ប្រការ១.-**

ត្រូវបានតែងតាំងជាប្រធាន និងសមាជិកនៃលេខាធិការដ្ឋានគណៈកម្មាធិការផលិតភាពកម្ពុជា “គ.ផ.ក.” ដែលមានសមាសភាពដូចខាងក្រោម÷

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ស៊ីសុវត្ថិ ជូវចំន្ទនោ** | ទីប្រឹក្សាឧបនាយករដ្ឋមន្ត្រីប្រចាំការ | ប្រធាន |
| ២-លោក | **ឃិន សុខ** | អគ្គនាយករងនៃវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ | សមាជិក |
| ៣-លោក | **នាយ រដ្ឋា** | ជំនួយការឧបនាយករដ្ឋមន្ត្រីប្រចាំការ | សមាជិក |
| ៤- លោក | **មុំ បញ្ញាហ៊ី** | ជំនួយការឧបនាយករដ្ឋមន្ត្រីប្រចាំការ | សមាជិក |
| ៥- លោក | **ណោ ម៉ាន់នី** | អនុប្រធាននាយកដ្ឋានគណនេយ្យជាតិនៃវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ | សមាជិក |
| ៦-លោក | **សៀង ចំណាន** | ប្រធានការិយាល័យសារពើពន្ធនៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ | សមាជិក។ |

**ប្រការ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការផលិតភាពកម្ពុជា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ២៧ ខែ ៨ ឆ្នាំ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- -ដូចប្រការ ៣
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ



www.pheakdeylaw.com